# ការដំឡើងអត្រាការប្រាក់គោលរបស់ធនាគារកណ្តាលអាមេរិក និងផលប៉ះពាល់

កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ធនាគារកណ្តាលអាមេរិកបានសម្រេចដំឡើងអត្រាការប្រាក់គោលចំនួន ២៥ពិន្ទុ ពី ០,២៥ ដល់ ០,៥% ។ ការដំឡើងនេះ បានបញ្ចប់នូវការរក្សាអត្រាការប្រាក់គោលឱ្យស្ថិតក្នុងកម្រិតស្ទើរស្មើសូន្យដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចក្នុងរយៈពេល៧ឆ្នាំ ហើយក៏ជាសញ្ញាមួយដែលធនាគារកណ្តាលអាមេរិកជឿជាក់ថា សេដ្ឋកិច្ចសហរដ្ឋអាមេរិកមានភាពរឹងមាំគ្រប់គ្រាន់ ។

ការដំឡើងអត្រាការប្រាក់គោលរបស់ធនាគារកណ្តាលអាមេរិក កំពុងក្លាយជាប្រធានបទមួយដ៏ក្តៅគគុកសម្រាប់ការពិភាក្សានានា ដោយសារតែការដំឡើងនេះអាចនឹងមានផលប៉ះពាល់ដល់លំហូរទុនវិនិយោគ អត្រាប្តូរប្រាក់ និងសន្ទនីយភាពនៅលើទីផ្សារអន្តរជាតិ ។

## ១)- មូលហេតុដែលធនាគារកណ្តាលអាមេរិកដំឡើងអត្រាការប្រាក់គោល

ធនាគារកណ្តាលអាមេរិកបានដំឡើងអត្រាការប្រាក់គោល បន្ទាប់ពីសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ មានភាពប្រសើរនិងអំណោយផល រួមមាន ៖

- អតិផរណាត្រូវបានរំពឹងថានឹងកើនឡើងដល់អត្រា ២% ដូចការរំពឹងទុកនៅក្នុងរយៈពេលមធ្យម
- ចំណាយរបស់អង្គភាពគ្រួសារនិងការវិនិយោគលើទ្រព្យសកម្មរូបវ័ន្ត បាននិងកំពុងកើនឡើងក្នុងអត្រាជាក់លាក់នាប៉ុន្មានខែចុងក្រោយនេះ ហើយវិស័យផ្ទះសម្បែងមានភាពប្រសើរជាងមុន ខណៈដែលការនាំចេញសុទ្ធមិនទទួលផលប៉ះពាល់ និង
- សូចនាករនានានៃទីផ្សារពលកម្មបច្ចុប្បន្ន រួមមាន ការទទួលបានការងារជាបន្តបន្ទាប់ និងការធ្លាក់ចុះអត្រានិកម្មភាពបានបង្ហាញសញ្ញាប្រសើរឡើងថែមទៀត ។

## ២)- ផលប៉ះពាល់ទូទៅនៃការបង្កើនអត្រាការប្រាក់គោល

ការដំឡើងអត្រាការប្រាក់គោលត្រូវបានគេរំពឹងតាំងពីដើមឆ្នាំ២០១៥ មកម្ល៉េះ ដូច្នេះការដំឡើងនាពេលថ្មីៗនេះ មិនធ្វើឱ្យទីផ្សារភ្ញាក់ផ្អើលខ្លាំងទេ ទន្ទឹមនេះ ការដំឡើងក៏បានគ្រោងថានឹងបន្តធ្វើឡើងបន្តិចម្តងៗជាលំដាប់ ។ ទោះជាយ៉ាងណាក៏ដោយ ឥទ្ធិពលនៃការដំឡើងនេះនៅតែមានឥទ្ធិពលទៅលើសេដ្ឋកិច្ចនិងទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ជាពិសេសនៅប្រទេសកំពុងងើបឡើង ។ ផលប៉ះពាល់ដែលអាចកើតឡើងជាយថាហេតុដោយសារការដំឡើងនេះ រួមមាន ៖

- ការដំឡើងអត្រាការប្រាក់គោលរបស់ធនាគារកណ្តាលអាមេរិក អាចជះឥទ្ធិពលលើខ្សែកោងអត្រាការប្រាក់ (yield curve) នៅលើទីផ្សារហិរញ្ញវត្ថុអន្តរជាតិដែលធ្វើឱ្យអត្រាការប្រាក់ទីផ្សារកើនឡើងសម្រាប់កម្ចីទាំងឡាយ ។ កំណើនអត្រាការប្រាក់នេះ នឹងធ្វើឱ្យវិនិយោគិនបង្វែរសាច់ប្រាក់ពីខាងក្រៅចូលមកសហរដ្ឋអាមេរិក ដើម្បីទទួលផលចំណេញខ្ពស់ជាងមុនជាមួយនឹងហានិភ័យទាប ។
- ហានិភ័យធ្ងន់ធ្ងរអាចកើតមានឡើងចំពោះប្រទេស ដែលមានបំណុលជាដុល្លារអាមេរិកច្រើនសន្ធឹកសន្ធាប់ ហើយវិនិយោគិនលក់ប័ណ្ណបំណុលដែលបានវិនិយោគ រួចបង្វែរការវិនិយោគទៅសហរដ្ឋអាមេរិកវិញ (មូលធនហូរចេញ) បន្ទាប់ពីការដំឡើងអត្រាការប្រាក់ ។ បញ្ហានេះនឹងធ្វើឱ្យ

រូបិយប័ណ្ណក្នុងស្រុកធ្លាក់ថ្លៃ ដែលនឹងធ្វើឱ្យបំណុលនៅក្នុងប្រទេសនោះកើនឡើងដោយស្វ័យប្រវត្តិ និងបង្កើនហានិភ័យដែលនាំទៅរកភាពក្ស័យធន ។

- នៅពេលដែលការវិនិយោគហូរចេញដោយប្រញាប់ប្រញាល់ ថ្លៃទ្រព្យសកម្មនឹងធ្លាក់ចុះ ហើយក្រុមហ៊ុនអាចប្រឈមនឹងការបាត់បង់សមត្ថភាពសងបំណុលនិងទីបំផុតឈានដល់ការក្ស័យធន ។

## ៣)- ឥទ្ធិពលនៃការដំឡើងអត្រាការប្រាក់គោលចំពោះកម្ពុជា

ចាប់តាំងពីវិបត្តិហិរញ្ញវត្ថុសកល សេដ្ឋកិច្ចអាស៊ីបានស្រូបយកសន្ទនីយភាពដ៏ច្រើនពីទីផ្សារអន្តរជាតិដោយសារការអនុវត្តគោលនយោបាយរូបិយវត្ថុរិត្បារកម្មរបស់ប្រទេសអភិវឌ្ឍន៍ ជាពិសេសសហរដ្ឋអាមេរិក ។ ដូច្នេះ ការដំឡើងអត្រាការប្រាក់គោលរបស់ធនាគារកណ្តាលអាមេរិកអាចនឹងបង្កើនហានិភ័យនៃការហូរចេញមូលធនពីតំបន់វិញ ។ ក៏ប៉ុន្តែដោយសារមូលដ្ឋានសេដ្ឋកិច្ចនិងភាពធន់នឹងវិបត្តិហិរញ្ញវត្ថុនៅអាស៊ីត្រូវបានពង្រឹង ជាពិសេសបន្ទាប់ពីវិបត្តិហិរញ្ញវត្ថុអាស៊ីឆ្នាំ ១៩៩៧-១៩៩៨ ផលប៉ះពាល់នៃការដំឡើងអត្រាការប្រាក់រំពឹងថានឹងមានកម្រិតតិចតួច ។

ចំពោះកម្ពុជា លំហូរមូលធនសម្រាប់ការវិនិយោគភាគច្រើនបានមកពីវិនិយោគផ្ទាល់បរទេសក្នុងតំបន់ ដែលមានចរិតលក្ខណៈជាវិនិយោគរយៈពេលវែងនិងមានស្ថិរភាព ។ ថ្វីបើប្រទេសកម្ពុជាប្រកាន់របបគណនីមូលធនសេរី ប៉ុន្តែទីផ្សារហិរញ្ញវត្ថុកម្ពុជាស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍនៅឡើយ និងមានជម្រើសវិនិយោគតិចសម្រាប់ការវិនិយោគរយៈកាលខ្លី ហេតុនេះកម្ពុជាមិនប្រឈមនឹងហានិភ័យនៃការហូរចេញភ្លាមៗនៃលំហូរមូលធនទេ ។ លើសពីនេះ កម្ពុជាមានកំណើនសេដ្ឋកិច្ចនិងមូលដ្ឋានម៉ាក្រូសេដ្ឋកិច្ចរឹងមាំ ដែលជាកត្តាទាក់ទាញលំហូរមូលធនមកកម្ពុជាក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ។ ចំពោះវិស័យសំណង់ ទោះបីជាមូលនិធិមួយចំនួនបានមកពីវិនិយោគិនបរទេសក៏ដោយ ប៉ុន្តែការបន្តទទួលបានប្រាក់ចំណេញខ្ពស់ក្នុងវិស័យនេះ គួបផ្សំនឹងកំណើនទាបនៃអត្រាការប្រាក់របស់ធនាគារកណ្តាលអាមេរិក ត្រឹម ០,២៥% នឹងមិនអាចបណ្តាលឱ្យវិនិយោគិនបរទេសដកទុនយ៉ាងឆាប់រហ័សពីប្រទេសកម្ពុជាទេ ។

ការកើនឡើងនៃអត្រាការប្រាក់អាចនាំឱ្យថ្លៃដើមមូលធនកើនឡើងដោយសារប្រទេសកម្ពុជាក៏មានកម្ចីពីទីផ្សារអន្តរជាតិដែរ ។ ដូច្នេះ ថ្លៃដើមនៃបំណុលអាចកើនឡើង ស្របនឹងការកើនឡើងនៃអត្រាការប្រាក់របស់អាមេរិក ប៉ុន្តែការកើនឡើងនេះអាចស្ថិតក្នុងល្បឿនយឺតនៅក្នុងរយៈពេលវែង ។ ម្យ៉ាងទៀត ប្រាក់បញ្ញើនិងបំណុលអនិវាសជន ដែលជាទ្រព្យអកម្មងាយនឹងរងឥទ្ធិពលពីការកើនឡើងនៃអត្រាការប្រាក់របស់អាមេរិក នៅមានកម្រិតទាបបើធៀបនឹងប្រភពទុនរបស់គ្រឹះស្ថានធនាគារ ។ ទន្ទឹមនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs) និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDIs) ដែលទទួលបានប្រភពទុនពីបរទេស ភាគច្រើនបានខ្ចីជាមួយនឹងអត្រាការប្រាក់ថេរនិងមានកាលវសាន្តវែង ។ ដូច្នេះ ក្នុងរយៈពេលខ្លី ថ្លៃដើមប្រភពទុនក្នុងវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុ នឹងមិនមានការប្រែប្រួលឡើយ ។

ការដំឡើងអត្រាការប្រាក់គោលរបស់ធនាគារកណ្តាលអាមេរិក នឹងអាចបង្កើនតម្លៃប្រាក់ដុល្លារអាមេរិកធៀបនឹងរូបិយប័ណ្ណក្នុងតំបន់ ។ ដោយតម្លៃប្រាក់រៀលមានស្ថិរភាពធៀបនឹងប្រាក់ដុល្លារអាមេរិក, ការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិកក៏មានន័យថា ប្រាក់រៀលនឹងឡើងថ្លៃធៀបនឹង

រូបិយប័ណ្ណផ្សេងៗទៀតដែរ ។ ដូច្នេះ ការឡើងថ្លៃនេះអាចនឹងមានឥទ្ធិពលដល់ភាពប្រកួតប្រជែងនៃការនាំចេញរបស់កម្ពុជា ។ ទោះជាយ៉ាងនេះក្តី ដោយសារការនាំចេញរបស់កម្ពុជាភាគច្រើនទៅកាន់សហរដ្ឋអាមេរិកនិងអឺរ៉ុបដែលសេដ្ឋកិច្ចកំពុងបន្តមានភាពប្រសើរឡើង ផលវិជ្ជមានដែលទទួលបានពីការកើនឡើងនៃអំណាចទិញនៅសេដ្ឋកិច្ចទាំងពីរនេះ អាចបន្ថយផលអវិជ្ជមានដែលបណ្តាលមកពីផលប៉ះពាល់ពីការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិកនិងប្រាក់រៀល ។

ការដំឡើងអត្រាការប្រាក់គោល នឹងធ្វើឱ្យមានការហូរមូលធនត្រឡប់ទៅសេដ្ឋកិច្ចអាមេរិកវិញ ដែលអាចនាំឱ្យប្រទេសជាច្រើនជួបនឹងបញ្ហាប្រឈមផ្នែកសន្ទនីយភាព ។ ចំពោះកម្ពុជា ដោយសារប្រព័ន្ធធនាគារមានទំនាក់ទំនងដោយផ្ទាល់តិចតួចជាមួយប្រព័ន្ធហិរញ្ញវត្ថុអាមេរិក ការហូរចេញទៅវិញនៃលំហូរមូលធនពីកម្ពុជាទៅសហរដ្ឋអាមេរិកវិញក៏នឹងមានទំហំតូចដែរ ។ ទោះជាយ៉ាងណា វិស័យធនាគារកម្ពុជាបានទទួលការវិនិយោគជាចម្បងពីប្រទេសក្នុងតំបន់ ដូច្នេះ កម្ពុជាអាចទទួលរងផលប៉ះពាល់ដោយប្រយោល នៅពេលដែលសេដ្ឋកិច្ចតំបន់ទទួលរងផលប៉ះពាល់ពីលំហូរចេញនៃមូលធន ប៉ុន្តែផលប៉ះពាល់ទាំងនេះអាចមានកម្រិតទាប ដោយសារតែសមាមាត្រនៃប្រភពហិរញ្ញប្បទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកម្ពុជាពីអនិវាសជនមានទំហំតូចនៅឡើយ ហើយបំណុលចំពោះអនិវាសជនផ្សេងៗមានរយៈពេលវែង ។ ម្យ៉ាងទៀត បច្ចុប្បន្ន ប្រព័ន្ធធនាគារកម្ពុជាមានកម្រិតសន្ទនីយភាពខ្ពស់ ដែលអាចទប់ទល់នឹងបញ្ហាសន្ទនីយភាពដែលអាចកើតឡើងជាយថាហេតុ ។